### សម្រេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមប្រជុំក្រុមពិគ្រោះយោបល់ជាមួយបណ្តាប្រទេស អង្គការនានា និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលបានផ្តល់ជំនួយ នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង ចាប់ពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និង ឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០០

## សេចក្តីសម្រេចលេខ ៣៤ សសរ
## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មជាផ្លូវការ នៅសាធារណរដ្ឋសិង្ហបុរី ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និង ឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០

**សេចក្តីសំរេចលេខ ៣៥ សសរ**

**ស្តីពីការប្រគល់ភារកិច្ចជូនទីប្រឹក្សា**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/០៩៥ ចុះថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការតែងតាំងទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- **យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការអចិន្ត្រៃយ៍**

**សំរេច**

**ប្រការ ១ :** ប្រគល់ភារកិច្ចជូនឯកឧត្តមឧត្តមសេនីយ៍ទោ ម៉ែន អ៊ិន ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី អោយទទួលតាមដាន និងក្តាប់សភាពការណ៍រួម ពិសេសសភាពការណ៍នៃគ្រោះមហន្តរាយនានានៅក្នុងខេត្តព្រៃវែង និងកំពង់ចាម ។

**ប្រការ ២ :** ឯកឧត្តម ម៉ែន អ៊ិន មានសិទ្ធិចូលរួមគ្រប់ពេលប្រជុំរបស់ថ្នាក់ដឹកនាំខេត្ត និងស្នងការដ្ឋាននគរបាលខេត្តទាំង ២ ដើម្បីរួមយោបល់លើបញ្ហាផ្សេងៗរបស់ខេត្ត ឬ ស្នងការដ្ឋាននគរបាល ខេត្ត ។

-ឯកឧត្តម ម៉ែន អ៊ិន មានសិទ្ធិជ្រើសរើសមន្ត្រីពី១ ទៅ ២នាក់ ដែលមានក្របខ័ណ្ឌស្រាប់ ជាជំនួយការ ។

-ឯកឧត្តម ម៉ែន អ៊ិន ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងារដែលសំរេចបានផ្ញើជូនឧបនាយករដ្ឋមន្ត្រី ស ខេង តាមរយៈខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ។